ធាតុនៃរបបដឹកនាំនៅស្រុកខ្មែរសព្វថ្ងៃ

សេរីការ

តាំងពី ស្រុកខ្មែរ ទទួលបាន ឯករាជ្យមក (ឆ្នាំ ១៩៥៣) របបដឹកនាំនៅស្រុកខ្មែរ មិនដែលមានធាតុជារបបដឹកនាំជាតិ តែជារបបដឹកនាំការពារតែផលប្រយោជន៍ រណ្ណ: បុគ្គល បុព្វសិទ្ធិ។ ដូចយ៉ាង របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញទី១ (១៩៤៧-១៩៥៦) ជារបបដឹកនាំ ដែលព្រះមហាក្សត្រ មិនព្រមបោះបង់ងារជា អភិសិត្តរាជ (roi sacré) ប្រើ គម្ពាស់ (levier) បីយ៉ាងដើម្បីរក្សាការពាររណ្ណ:ក្សត្រ គឺ ប្រពៃណី សាសនា និងសិទ្ធិព្រះរាជ ប្រឆាំងនឹងរដ្ឋធម្មនុញ្ញជាតិ ដែលមាន ប្រជាពលរដ្ឋ ជា ម្ចាស់អំណាច។ ចំណែក របបសង្គមរាស្ត្រនិយម (១៩៥៦-១៩៧០) ជារបបរាជានិយមផ្តាច់ការ មានប្រមុខរដ្ឋពីរ គឺ ព្រះមហាក្សត្រ និង ស្តេចជាព្រះប្រមុខរដ្ឋ ពាក់ងារ អស់មួយជីវិត សំរាប់ដឹកនាំនយោបាយជាតិ ដោយបំពាន លើរដ្ឋធម្មនុញ្ញ ដើម្បីការពារ រាជអំណាច ដែលជាការនាំឲ្យខូចប្រយោជន៍ជាតិ។ របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ជា របបដឹកនាំ ប្រឈរមុខនឹងការឈ្លានពានបូរណភាពទឹកដី ពីសំណាក់ឃ្លីនកុម្មុយនិស្ត មានខ្មែរក្រហម និង ខ្មែររាជានិយម ជាដំនួយ ជួយឃ្លីនវាយប្រហារខ្មែរគ្នាឯង ដែលនាំអោយមាន បំណាក់ (fracture) សាមគ្គីភាពខ្មែរ នៅចំពោះមុខសត្រូវជាតិ។ របបសាធារណរដ្ឋ មានគោលដៅត្រឹមត្រូវតែខ្វះពេលវេលា និង មធ្យោបាយពេញលេញ

សំរាប់ការពារជាតិ នៅក្នុងសង្គ្រាមដំបន់ ដែលជាសង្គ្រាមរបស់
មហាអំណាចអាមេរិកាំង នឹង លោកកុម្មុយនិស្ត នៅឥណ្ឌូចិន។
របបដឹកនាំខ្មែរក្រហម ជា ការបដិវត្តន៍ ជា ការហិនហោចសព្វ
គ្រប់នៅក្នុងសង្គម ព្រោះតែមានគោលដៅ រំលើងអោយអស់
ន្ទូរ សណ្ដាប់ធ្នាប់ជាតិចាស់ ដើម្បី កសាងសង្គមថ្មី គឺសង្គម
កុម្មុយនិស្ត ជាសុក្រិត។ គេអាចទុកបដិវត្តន៍ របស់ពួកខ្មែរ
ក្រហម ជា ការបំផ្លាញជាតិតែម្តង ដែលខ្មែរយើងអោយឈ្មោះ
ថា ជារបបប្រល័យជាតិសាសន៍ខ្លួនឯង។ ដប់ឆ្នាំ នៅក្រោមការ
កាន់កាប់កងទ័ពយួន (១៩៧៩-១៩៨៩) អ្នកដឹកនាំយួន ប្រើ
គ្រប់មធ្យោបាយ ដើម្បី កំទិចអោយអស់ ន្ទូរព្រលឹងជាតិខ្មែរ
ដែលជាបស្សាស: (volume d'air inspiré) នៃការសង្ឃឹម របស់ជនជាតិ
ខ្មែរ លើអនាគត ប្រកបដោយរិបុលភាព នៃប្រជាជាតិខ្លួន។
យួន គេទុកជ័យជំនះ ៧ មករា ១៩៧៩ ជា ជោគជ័យ នៃប្រជា
ជាតិយួន លើប្រជាជាតិខ្មែរ តែតាមការពិត វាគ្រាន់តែជាវិជ័យ
(victoire spéciale) នៃកងទ័ពយួន លើកងទ័ពខ្មែរក្រហម ដែលជា
កងទ័ពមួយគ្មានសមត្ថភាព និងគ្មានការគាំទ្រពីប្រជាពលរដ្ឋ
សោះឡើយ ដូច្នេះខ្មែរយើងត្រូវទុកបរាជ័យនេះ ជា ទុព្ធលភាព
នៃពួកខ្មែរក្រហមតែម្នាក់ឯងនៅចំពោះមុខសត្រូវជាតិ ព្រោះ
វាមិនមែន ជា មូលហេតុ នៃគុណវិបត្តិ របស់ប្រជាពលរដ្ឋនោះ
ទេ។ សុំខ្មែរយើងកុំយកបរាជ័យរបស់ពួកខ្មែរក្រហម មកធ្វើ ជា
ហិនមាន:របស់ខ្លួន នៅចំពោះមុខ ពួកយួនកុម្មុយនិស្ត។ ការ
រឹលក្រឡប់ នៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញទី២ នៅឆ្នាំ
១៩៩៣ ដែលមាន សម្តេច សីហនុ ជា តួឯកនយោបាយ

ដដែល ជា ផ្ទួលមិនល្អ សំរាប់ប្រជាជាតិខ្មែរ ព្រោះតួឯកចាស់នេះ ជា អ្នកចូលចិត្តដុតផ្ទះផង ហើយបន្ទាប់មក ធ្វើ ជា អ្នកពន្លត់អគ្គីភ័យផង តែកាលណា គាត់ដុតផ្ទះអោយនេះម្តងៗ គាត់ឈរមើលចាំផ្ទះនេះជិតអស់ទើបគាត់ប្រញាប់ប្រញាលធ្វើ ឬកជាអ្នកពន្លត់ភ្លើងហើយហៅ ចិន/យួនកុម្មុយនិស្ត អោយមកជួយជាឈ្មួញបោយយកប្រយោជន៍ ជា អច្ចិន្ទ្រៗ (butin)។ និវត្តន៍ នៃរបបរាជានិយម ដែលមានស្តេចសីហនុ ជា ប្រមុខ មានន័យ ជាការរក្សាឥទ្ធិពល ចិន/យួនកុម្មុយនិស្ត នៅស្រុកខ្មែរ ដែលជាមេក្រមី សំរាប់សម្លាប់បន្ទិចម្តងៗព្រលឹងជាតិខ្មែរ ព្រោះ សម្តេច សីហនុ គាត់មិនដែលទុកគាត់ជាខ្មែរ ដ្ឋិតធម្ម ជាតិរបស់គាត់ គឺជា បុគ្គលអាត្មានិយម ហើយមានគំនុំនឹងជាតិខ្មែរជានិច្ច ដូចយ៉ាង ទ្រង់ គាំទ្ររបបខ្មែរក្រហម ដែលជា របបប្រល័យជាតិសាសន៍ខ្លួនឯង ហើយតមកទៀត គាត់ប្រស់ របបបច្ចុប្បន្ន ដែលជា របបរណបយួនកុម្មុយនិស្តសុទ្ធសាត ដែលខ្មែរភាគច្រើន គិតនៅក្នុងចិត្តថាជា របបតិរច្ឆាន ព្រោះ ជាបាតដៃទី៣សម្លាប់ខ្មែរគ្នាឯងដើម្បីការពារប្រយោជន៍យួន។ ដូច្នេះ ធាតុ នៃតិរច្ឆាន វាមាននៅក្នុង ធាតុសារសេស (នៅ សល់) ពីធាតុសីហនុនិយមតាំងពីយូរយារមកហើយ ព្រោះ រាល់ បទឧក្រិដ្ឋ មានកើតឡើងនៅស្រុកខ្មែរ តាំងពីទសវត្សរ៍៧០ មក ដែលជា ឧន្ទាកា (chemin du mal) គឺជា កម្មវិបាក នៃ នយោបាយឃ្លៀងឃ្លាតពីប្រយោជន៍ជាតិ របស់សម្តេច សីហនុ។ យើងអាច សន្និដ្ឋានបានថា លក្ខណៈ នៃតិរច្ឆាន នៃរបប បច្ចុប្បន្ន ជា ល្បាយ នូវ អន្ទការនិយម នៃពួកខ្មែរជាប់ឃ្នាង

យួន ពួកខ្មែរសីហនុនិយម និងពួកខ្មែរអាត្មានិយម ដែលជា កុកតែ (cocktail) របស់ចិន/យួនកុម្មុនិស្តលាយអោយប្រជាពលរដ្ឋ ខ្មែរ ពិសា ជាអសិរពិស តាំងពីឆ្នាំ ១៩៧០ មកម្លេះ។ ការលើក យកធាតុ នៃតិរច្ឆាន នៃរបបដឹកនាំសព្វថ្ងៃមកនិយាយ វា គ្រាន់តែមានភាព ជាការដាស់សតិខ្មែរ អោយពិចារណាជាថ្មី លើ ឫសគល់ នៃអកុសលរបស់ប្រជាជាតិខ្មែរ ក្នុង វិបរិត[1] ទុកជាវិនាដកម្មជាតិគឺអំពើឃាតកម្មលើរូបមហាបុរស កែមឡី តែប៉ុណ្ណោះ។ តែអកុសលនេះ វានៅមាន ជីវិតជានិច្ច នៅក្នុង ប្រជាជាតិខ្មែរព្រោះ អ្នកនយោបាយខ្មែរគ្រប់និន្នាការ គាត់ តែងតែគេចជានិច្ចនៅចំពោះមុខអ្វី ដែលអាចជាការរំខាន ដល់សេចក្ដីសុខផ្ទាល់ខ្លួន នាំអោយ គាត់ក្ពុលគំនិត ព្រោះមិន ហ៊ានយកឫសគល់ នៃអកុសល របស់ប្រជាជាតិខ្មែរមកធ្វើបច្ច វេក្ខណ:[2] លើកត្តាធំពីរយ៉ាង គឺ៖ ១. អកុសល ដែលមាន ចិន/ យួនកុម្មុយនិស្ត ជាអ្នកចិញ្ចឹមឲរស់ជានិច្ចនៅស្រុកខ្មែរ ២. ចរិត ខ្មែរ[3]ខ្លួនឯងតែម្តង ដែលជា ឧបសគ្គសំខាន់ សំរាប់យល់ដឹង នូវអ្វីដែលខ្លួន គិតថា ខ្លួនជាអ្នកចេះដឹងពិតប្រាកដ។ រួមសេ ចក្ដីមកគឺថា ត្រូវស្គាល់សត្រូវ និងខ្លួនឯងឲច្បាស់ ពុំនោះគឺអ្វី ដែលខ្មែរយើងបានគិត ហើយកំពុងធ្វើ វាអាចនឹង កំពុង សម្លាប់ជាតិខ្លួនឯង ដោយមិនដឹងខ្លួន។ បើដូច្នេះមែន គឺ ខ្មែរ សព្វគ្នា ជា តិរច្ឆាន ចំពោះជាតិខ្លួនតែម្តង។ ដូច្នេះ តើខ្មែរ

[1] វិបរិត ; Bouleversement dû à un évènement grave។

[2] បច្ចវេក្ខណ: ; examen en profondeur។

[3] សូមអានសៀវភៅ លោក ប៊ុណ្ណចន្ទ ម៉ុល : **ចារិតខ្មែរ**។

យើង នឹងអាចរំលើងរបបដឹកនាំតិរច្ឆានសព្វថ្ងៃម្តេចបាន បើ ខ្មែរយើងម្នាក់ៗតាំងខ្លួនជាអ្នកស្នេហាជាតិ តែគ្មានគុណធម៌ នៅក្នុងស្មារតី ? គុណកថា តែគ្មានការអនុវត្តន៍ គឺជាទម្រង នៃតិរច្ឆានមួយបែបដែរ ព្រោះ គុណប្រយោជន៍ (enjeu) នៃការ រំដោះជាតិពីអាណានិគមយួន និងអំណាចផ្តាច់ការ គឺជា ការស ង្គ្រោះជាតិ ពីគ្រោះថ្នាក់ដល់អាយុជីវិតនៃប្រជាជាតិខ្មែរ។ ដូច្នេះ ការពិភ្សាសា លើធាតុតិរច្ឆាន នៃរបបដឹងនាំសព្វថ្ងៃ វាគ្រាន់តែ ជា ការពិភ្សាសាជារិទ្ធ (faux débat) តែប៉ុណ្ណោះ ព្រោះថា ទង្វើគ្រប់ បែបយ៉ាង ដែល របបដឹកនាំសព្វថ្ងៃ កំពុងធ្វើ វាហួសពីអំពើ តិរច្ឆានទៅទៀត ព្រោះ អំពើ តិរច្ឆាន វាអាច ប្រព្រឹត្តិឡើង ដោយមនុស្សឆ្កួត តែ បទឧក្រិដ្ឋនៅស្រុកខ្មែរ វាមានការរៀបចំ ច្បាស់លាស់ ពីសំណាក់យួនកុម្មុយនិស្ត ដោយប្រើ ពេជ្ឈឃាត ជា ជនខ្មែរ ជាបាតដៃទី៣ សំរាប់សម្លាប់ខ្មែរ។ ដូច្នេះ ទង្វើនេះ វា រំលេច នូវរូបភាពពិតប្រាកដ ជា ឃាតកម្មប្រឆាំងនឹងមនុស្ស ជាតិ មាន អ្នកទទួលខុសត្រូវច្បាស់លាស់ នៅចំពោះមុខ ច្បាប់ ជាតិ និងអន្តរជាតិ និងមានចារទុក នៅក្នុងប្រវត្តិសាស្ត្រជាតិ ខ្មែរសំរាប់កូនខ្មែរក្នុងឧត្តរកាល ទុកជាស្មារតី នៃជនជាតិខ្មែរ។